ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍សិក្ខាសាលា

## ក្រុមប្រឹក្សាបច្ចេកទេសលើកទី១០ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០

រៀបចំដោយ៖ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន
នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឧបត្ថម្ភដោយ៖ ថវិកាជាតិ

## ១. សេចក្តីផ្តើម៖

នៅព្រឹកថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំសិក្ខាសាលាក្រុមប្រឹក្សាបច្ចេកទេសលើកទី១០សម្រាប់ឆ្នាំ២០២០ នៅបន្ទប់ប្រជុំ"ខ"នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ក្រោមការដឹកនាំរបស់ **ឯកឧត្តម ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការអញ្ជើញចូលរួមពីសមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការមួយចំនួនដែលពាក់ព័ន្ធ។ ក្នុងនោះសមាជិកនៅតាមបណ្តាក្រសួង និងអង្គការពាក់ព័ន្ធនៅក្រុងភ្នំពេញត្រូវបានមកចូលរួមផ្ទាល់នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយឡែកសមាជិកនៅតាមខេត្តចូលរួមតាមរយៈវីដេអូខនហ្វើរេន(Blue Jeans)។

## ២. គោលបំណងនៃកិច្ចប្រជុំ៖

ចែករំលែកចំណេះដឹង ការអនុវត្តវិធីសាស្ត្រក្នុងការធ្វើតេស្តឈាមរកមេរោគអេដស៍ដោយខ្លួនឯង (SOP of HIV/AIDS self testing) ដល់សមាជិកក្រុមប្រឹក្សាបច្ចេកទេសនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីរួមចំណែកក្នុងការលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍ និងបញ្ចប់ជំងឺអេដស៍ដែលជាការគំរាមកំហែងសុខភាពសាធារណៈ ដោយឈានទៅសម្រេចគោលដៅ ៩៥-៩៥-៩៥ ក្នុងឆ្នាំ២០២៥ តាមរយៈការផ្តល់បន្ថែមនូវជម្រើសនានា ក្នុងការធ្វើតេស្តរកមេរោគអេដស៍នៅប្រទេសកម្ពុជា ជាពិសេសការធ្វើតេស្តដោយខ្លួនឯង (HIV Self Testing = HIVST) និងបង្កភាពងាយទទួលយកបានកាន់តែច្រើនសម្រាប់អ្នកដែលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍។

## ៣. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ

ជាកិច្ចចាប់ផ្តើម **ឯកឧត្តម ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានមានមតិស្វាគមន៍ និងថ្លែងអំណរគុណដល់សមាជិក សមាជិកាក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ដែលបានអញ្ជើញចូលរួមផ្ទាល់ និងតាមរយៈវីដេអូខនហ្វើរេន។ នាឱកាសនោះឯកឧត្តម ក៏បានជម្រាបជូនសមាជិកទាំងអស់ឱ្យបានយល់ថា ការតាមដាន ត្រួតពិនិត្យ និងការអនុវត្តផែនការសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ គឺជាការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាបច្ចេកទេស ដូច្នេះហើយទើបសិក្ខាសាលាក្រុមប្រឹក្សាបច្ចេកទេសត្រូវរៀបចំជាប្រចាំរៀងរាល់មួយខែម្តង ដើម្បីឱ្យការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ មានប្រសិទ្ធភាពក្នុងការលុបបំបាត់ការឆ្លងថ្មី គ្មានការស្លាប់ដោយសារជំងឺអេដស៍ និងគ្មានការរើសអើងដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ម្យ៉ាងវិញទៀត សិក្ខាសាលានេះបានចែករំលែកនូវការយល់ដឹង ក៏ដូចជាបទពិសោធន៍ពីគ្នាទៅវិញទៅមក ព្រមទាំងសំណូមពរនានា ឬក៏មានបញ្ហាទាក់ទងនឹងបញ្ហាអេដស៍លើកយកមកពិភាក្សាដើម្បីរកដំណោះស្រាយរួមគ្នា។

បន្ទាប់មក លោកវេជ្ជ. **ជា ច័ន្ទកុសលមុនី** ប្រធានផ្នែក VCCT នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងលោកស្រី **និត សុផា** តំណាងអង្គការ FHI-360 បានធ្វើបទបង្ហាញរួមគ្នាអំពីនិយាម បែបបទសម្រាប់អនុវត្តវិធីសាស្ត្រធ្វើតេស្តរកមេរោគអេដស៍ដោយខ្លួនឯងនៅក្នុងប្រទេសកម្ពុជា ក្នុងនោះលោក ក៏បានជម្រាបជូនអំពីសាវតានៃការរៀបចំនិយាមបែបបទនេះ៖

- គម្រោងកម្មវិធីធ្វើតេស្តដោយខ្លួនឯង (HIVST= HIV Self testing) ត្រូវបានសាកល្បងចាប់ពីខែ តុលាឆ្នាំ២០១៨ ដល់ ឆ្នាំ២០១៩
- កម្មវិធីអនុវត្តការធ្វើតេស្តមាន៣របៀបគឺ **តេស្តមានអ្នកជួយ តេស្តមិនមានអ្នកជួយ និងតាមអនឡាញ** ជាលទ្ធផលបង្ហាញថា កំណើននៃអត្រាអ្នកចូលរួមធ្វើតេស្តក្នុងគម្រោងកម្មវិធី ធៀបជាមួយចំនួន ប៉ាន់ប្រមាណលើក្រុមប្រជាជនគន្លឹះចំនួន ៣ (MSM, TG និង EW)៖ អ្នកមិនដែលបានធ្វើតេស្ត សោះ បានមកធ្វើតេស្តមានចំនួន ៧០.៧% និងមានលទ្ធផលប្រតិកម្មតេស្តជារួមចំនួន៥១(= ៥.៩%) ហើយអ្នកដែលមានតេស្តប្រតិកម្មស្ទើរតែទាំងអស់(ចំនួន៥១នាក់)បានចុះឈ្មោះក្នុង សេវាហើយ។ ដូច្នេះតាមការសិក្សា បង្ហាញឱ្យឃើញថា ក្រុមទាំងបីនេះនៅតែមាន អត្រាខ្ពស់ ប្រឈមទៅនឹងការឆ្លងមេរោគអេដស៍ ក្នុងនោះ (MSM=7.9%, TG=10,0% និងEW=2,5%)។

ផ្អែកលើលទ្ធផលនៃការសិក្សាខាងលើ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ ក៏បានរៀបចំ**និយាមបែបបទសម្រាប់អនុវត្តវិធីសាស្ត្រធ្វើតេស្តរកមេរោគអេដស៍នៅប្រទេសកម្ពុជា** និងបានអនុម័តដាក់ឱ្យប្រើប្រាស់ដោយក្រសួងសុខាភិបាលនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០។

គោលបំណងរួម៖ គឺដើម្បីបង្កើតគោលនយោបាយ និងវិធីសាស្ត្រជុំវិញការដាក់ឱ្យដំណើរការ និង ការអនុវត្តការធ្វើតេស្តរកមេរោគអេដស៍ដោយខ្លួនឯង ដើម្បីបង្កើតជម្រើសធ្វើតេស្តឈាមរកមេរោគអេដស៍ បន្ថែមទៀត រួមចំណែកក្នុងការកាត់បន្ថយឧបសគ្គនានា ក្នុងការទទួលបានការធ្វើតេស្តឈាមរកមេរោគ អេដស៍ចំពោះអ្នកដែលប្រឈមនឹងការឆ្លងមេរោគអេដស៍។

ដូច្នេះសួរថា តើការធ្វើតេស្តរកមេរោគអេដស៍ដោយខ្លួនឯងគឺជាអ្វី?

គឺជាដំណើរការមួយដែលបុគ្គលម្នាក់ប្រមូលសំណាកសម្រាប់ធ្វើតេស្ត បន្ទាប់មកធ្វើតេស្តដោយខ្លួនឯង និងបក ស្រាយលទ្ធផលតេស្តនៅទីកន្លែងឯកជនតែម្នាក់ឯង ឬជាមួយនរណាម្នាក់ដែលបុគ្គលនោះទុកចិត្ត។ដោយឡែក OralQuick ជាឧបករណ៍ធ្វើរោគវិនិច្ឆ័យវេជ្ជសាស្ត្ររកមេរោគអេដស៍ ដែលត្រូវប្រើប្រាស់ សម្រាប់ធ្វើតេស្តដោយ ខ្លួនឯង រកអង្គបក្ខជិបក្ខប្រាណ HIV-1 និង HIV-2 ដែលជាសារជាតុរាវមាននៅក្នុងមាត់មនុស្ស។

ដូច្នេះការធ្វើតេស្តរកមេរោគអេដស៍ដោយខ្លួនឯង មានន័យថា មនុស្សម្នាក់អាចប្រមូលសំណាករបស់ខ្លួនដោយខ្លួនឯង(សារធាតុរាវផ្ទាល់មាត់ ឬឈាម) និងបកស្រាយលទ្ធផលនៅក្នុងកន្លែងឯកជនតែម្នាក់ឯង ឬជាមួយនរណាម្នាក់ដែលជឿទុកចិត្ត(ទាំងការធ្វើតេស្ត ប្រមូលយកសំណាក និងអានលទ្ធផល)។

ការធ្វើតេស្តរកមេរោគអេដស៍ដោយខ្លួនឯង(HIVST) មានគោលការណ៍សំខាន់ៗ៖

- លទ្ធផលតេស្តដែលមានប្រតិកម្ម គឺគ្រាន់តែជាលទ្ធផលតេស្តដំបូង
- លទ្ធផលតេស្តដែលគ្មានប្រតិកម្ម ត្រូវបានចាត់ទុកមិនមានឆ្លងមេរោគអេដស៍
- មិនគួរធ្វើតេស្តចំពោះនរណាម្នាក់ដែលកំពុងប្រើឱសថប្រឆាំងមេរោគអេដស៍(ART) ទេ
- អ្នកដែលមិនយល់ច្បាស់អំពីវិធីសាស្រ្ត ឬពីការបកស្រាយលទ្ធផលតេស្ត

ក្រុមគោលដៅដែលត្រូវធ្វើតេស្តរកមេរោគអេដស៍ដោយខ្លួនឯង៖

- ស្ត្រីធ្វើការនៅសេវាកម្សាន្តសប្បាយ រួមទាំងស្ត្រីឯករាជ្យ និងនៅតាមសួន (FEW)
- បុរសរួមភេទជាមួយបុរស(MSM) រួមទាំងបុរសរកស៊ីផ្លូវភេទ (MSMSW)
- អ្នកបំប្លែងភេទ រួមទាំងអ្នកបំប្លែងភេទដែលរកស៊ីផ្លូវភេទ (TGSW)
- ក្រុមអ្នកចាក់គ្រឿងញៀន (PWID)
- ដៃគូរបស់ក្រុមប្រឈម

គុណសម្បត្តិ និងគុណវិបត្តិនៃការធ្វើតេស្តរកមេរោគអេដស៍ដោយខ្លួនឯង

គុណសម្បត្តិ៖

- អាចទទួលធ្វើបាន និងងាយស្រួល
- បង្កើនចំនួនអ្នកធ្វើតេស្តឈាមរកមេរោគអេដស៍
- កាត់បន្ថយនូវឥរិយាបថប្រព្រឹត្តប្រឈមនឹងការរួមភេទ
- មនុស្សភាគច្រើនចង់ធ្វើតេស្តដោយខ្លួនឯងដោយមិនចង់មានជំនួយច្រើន

គុណវិបត្តិ៖

- ត្រូវការប្រព័ន្ធតាមដានរឹងមាំ ដើម្បីជៀសវាងបាត់ព័ត៌មាន ជាពិសេសបាត់ក្នុងករណីបញ្ជាក់តេស្ត និងបញ្ជូនទៅសេវាព្យាបាលប្រសិនលទ្ធផលបញ្ជាក់វិជ្ជមាន
- ត្រូវរៀបចំជាមុនដើម្បីដោះស្រាយបញ្ហាផ្សេងៗដែលអាចកើតឡើងទោះជាមានដោយកម្រក៏ដោយ។

នាឱកាសនោះ ឯកឧត្តម អគ្គលេខាធិការប្រធានអង្គប្រជុំបានបន្តថា ទោះជាបច្ចុប្បន្នស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍ មានអត្រាថយចុះនៅប្រទេសកម្ពុជាយើងក៏ពិតមែន ប៉ុន្តែតាមការបកស្រាយនៅតែជាបញ្ហាសម្រាប់ក្រុមប្រជាជនគន្លឹះដដែល ពិសេសក្រុមបុរសរួមភេទជាមួយបុរស និងក្រុមបំប្លែងភេទនៅតែមានអត្រាឆ្លងមេរោគអេដស៍កើនឡើងខ្ពស់គួរឱ្យព្រួយបារម្ភ ដូច្នេះចំពោះក្រុមការងារបង្ការមិនអាចបន្ធូរដៃបានទេ បើសិនជាយើងមិនយកចិត្តទុកដាក់បន្ថែម វានឹងផ្ទុះឡើងវិញ ព្រោះមេរោគអេដស៍មិនទាន់បានរកឃើញឱសថព្យាបាលនៅឡើយទេ។

ចុងបញ្ចប់ ឯកឧត្តមប្រធាន ក៏បានថ្លែងអំណរគុណចំពោះ លោកវេជ្ជ. ជា ច័ន្ទកុសលមុនី និងលោកស្រី និត សុផា ព្រមទាំងសមាជិក សមាជិកាទាំងអស់ដែលបានចូលរួមក្នុងអង្គសិក្ខាសាលានាពេលនេះ និងបានកំណត់យកសិក្ខាសាលាលើកក្រោយនៅថ្ងៃពុធ ១០កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ ដោយបញ្ជាក់ថា សមាជិកដែលនៅទីក្រុងភ្នំពេញនឹងមកចូលរួមនៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ផ្ទាល់ ដោយឡែកសមាជិកនៅតាមខេត្តចូលរួមតាមរយៈវីដេអូ-ខនហ្វើរេន(Blue Jeans)។

ថ្ងៃព្រហស្បតិ៍ ០៣រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២០

**អ្នកធ្វើរបាយការណ៍**

**ស៊ុំ ផល្លា**

បានពិនិត្យត្រឹមត្រូវ

**ប្រធាននាយកដ្ឋាន**

**ទាក់ទង និងចលនាប្រភពធនធាន**

បានឃើញ និងពិនិត្យផ្ទៀងផ្ទាត់

**អគ្គលេខាធិការ**

**ឈឹម យិនដារ៉េត**